# ក្រុមសហគមន៍ផលិតសម្ភារៈប្រើប្រាស់ និងវត្ថុអនុស្សាវរីយ៍ធ្វើពីឫស្សី រីករាយដោយឃើញមុខរបរអាជីវកម្មរបស់ពួកគាត់ មានដំណើរការល្អ

## គម្រោងអភិរក្សដែនជម្រកសត្វព្រៃកែវសីមាគាំទ្រដោយទីភ្នាក់ងារជំនួយអាមេរិក USAID ជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍តាមរយៈការបង្កើនប្រាក់ចំណូលពីការប្រមូលផលនិងកែច្នៃឫស្សីប្រកបដោយនិរន្តរភាព។



សកម្មភាពកែច្នៃឫស្សី



រោងសិប្បកម្មប្រក់ដំបូលឫស្សី



កែវទឹកធ្វើពីឫស្សី

ចំណូលពីការលក់វត្ថុអនុស្សាវរីយ៍ និងសម្ភារៈប្រើប្រាស់ធ្វើពីឫស្សី ដែលផលិតដោយក្រុមអាជីវកម្មកែច្នៃឫស្សីខ្នាតតូចនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ បានកើនឡើងជិតបួនដងពី ២១២ដុល្លារក្នុងឆ្នាំ២០១៩ ដល់ ៨០៦ដុល្លារក្នុងឆ្នាំ ២០២០។

កំណើននេះបានកើនឡើងដោយសារ ក្រុមអាជីវកម្មឫស្សីខ្នាតតូចនេះ បានផលិតនិងកែច្នៃបន្ថែមឱ្យមានផលិតផលច្រើនប្រភេទផ្សេងគ្នា និងបានកែលម្អគុណភាពនៃផលិតផលឫស្សីរបស់ពួកគាត់ ក្រោយពីបានទទួលវគ្គបណ្តុះបណ្តាលជំនាញកែច្នៃឫស្សី ដែលគាំទ្រដោយទីភ្នាក់ងារជំនួយអាមេរិក USAID ក្រោមគម្រោងអភិរក្សដែនជម្រកសត្វព្រៃកែវសីមា ព្រមទាំងមានការផ្លាស់ប្តូរឥរិយាបថរបស់អ្នកប្រើប្រាស់ពីការឈប់ប្រើប្រាស់សម្ភារៈប្លាស្ទិក មកប្រើប្រាស់សម្ភារៈផលិតពីឫស្សីវិញ។

ក្រុមអាជីវកម្មកែច្នៃឫស្សីខ្នាតតូច«ស្រែព្រះ» គឺជាសហគ្រាសសហគមន៍ បានបង្កើតឡើងកាលពីខែកញ្ញា ឆ្នាំ ២០១៨ ដោយទទួលបានការគាំទ្រថវិកាពីទីភ្នាក់ងារជំនួយអាមេរិក USAID គម្រោងរេដបូក និងគម្រោងកាំប៉ាស់ ក្នុងគោលបំណង (១) ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សមាជិកនៃក្រុមកែច្នៃ (២) បង្ហាញអំពីការប្រើប្រាស់ធនធានឫស្សីនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះប្រកបដោយនិរន្តរភាព និង(៣) លើកទឹកចិត្តសហគមន៍ឱ្យដាំស្តារឫស្សីឡើងវិញនៅលើតំបន់ដែលបានកាប់បំផ្លាញស្ថិតក្នុងសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ។ សកម្មភាពអាជីវកម្មសំខាន់ៗរបស់ក្រុមកែច្នៃឫស្សីនេះ រួមមាន ការបណ្តុះនិងដាំឫស្សីនៅលើតំបន់ដែលបានកាប់បំផ្លាញ និងផលិតសម្ភារៈប្រើប្រាស់ធ្វើពីឫស្សីសម្រាប់លក់។

ក្រុមនេះមានសមាជិក ២៧នាក់ ក្នុងនោះមានស្ត្រី ១៥នាក់ មកពីភូមិចំនួនបីគឺ ពូចា ពូគង់ និងអូរប្រាស្ថិតក្នុងឃុំស្រែព្រះស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ សម្ភារៈប្រើប្រាស់ដែលក្រុមនេះផលិត រួមមាន កំសៀវទឹក កែវទឹកធំមានដៃ ពែងទឹក ប្រដាប់ដាក់ទៀនក្រអូប ប្រអប់ដាក់ក្រដាសជូតដៃ ពម្ពក់ព្យួរខោអាវ ឧបករណ៍បំពងសម្លេងទូរស័ព្ទដៃ ប្រដាប់ដាក់ប៊ិច បំពង់សម្រាប់ដាក់គ្រឿងធ្វើម្ហូប(ផ្ទះបាយ) ថូផ្កា និងសម្ភារៈជាច្រើនផ្សេងទៀត។

ក្រុមអាជីវកម្មកែច្នៃឫស្សីខ្នាតតូច «ស្រែព្រះ» ត្រូវបានបង្កើតឡើងនិងគាំទ្រដោយទីភ្នាក់ងារជំនួយអាមេរិក USAID ក្រោមគម្រោងអភិរក្សដែនជម្រកសត្វព្រៃកែវសីមា ដែលអង្គការ WCS ជាអ្នកអនុវត្តគម្រោងនេះ។ បច្ចុប្បន្ន ក្រុមនេះកំពុងគ្រប់គ្រងព្រៃឫស្សីទំហំ ៦៩ហិកតា ស្ថិតនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិស្រែព្រះ ក្នុងនោះមានពូជឫស្សី ៤ប្រភេទគឺ ឫស្សីថ្ងរ ឫស្សីព្រៃ ឫស្សីខ្លី និងឫស្សីរលាក។ សមាជិកក្រុមនេះ បានទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសប្រមូលផលឫស្សីប្រកបដោយនិរន្តរភាព ការរៀបចំធ្វើផែនការអាជីវកម្ម គ្រប់គ្រងសារពើភ័ណ្ឌឫស្សី ការបែងចែកផលប្រយោជន៍ និងការគ្រប់គ្រងហិរញ្ញវត្ថុ។

សមាជិកក្រុម ប្រើប្រាស់ចំណូលបានពីការលក់ផលិតផលឫស្សីនេះសម្រាប់ទ្រទ្រង់ការចំណាយក្នុងគ្រួសារ និងរក្សាទុកមួយផ្នែកសម្រាប់ចំណាយលើការងារអភិរក្សព្រៃឈើនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ ក្រុមនេះសង្ឃឹមថានឹងបន្តលក់ផលិតផលឫស្សីកែច្នៃ ពង្រីកផ្ទៃដីដាំឫស្សីបន្ថែមដើម្បីស្តារតំបន់ដែលបានកាប់បំផ្លាញឡើងវិញនៅទូទាំងសហគមន៍តំបន់ការពារធម្មជាតិ និងសិក្សាវាយតម្លៃអំពីតម្រូវការទីផ្សារ និងលទ្ធភាពក្នុងការផលិតប្រភេទសម្ភារៈឫស្សីផ្សេងៗទៀត៕

ខ្លឹមសារនៅក្នុងអត្ថបទនេះ គឺជាការទទួលខុសត្រូវរបស់អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ហើយមិនឆ្លុះបញ្ចាំងអំពីការយល់ឃើញរបស់ទីភ្នាក់ងារជំនួយអាមេរិក ឬក៏រដ្ឋាភិបាលអាមេរិកឡើយ។